ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍សិក្ខាសាលា

## ក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦

រៀបចំដោយៈ នាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

ឧបត្ថម្ភដោយៈ ថវិកាជាតិ

## **១. សេចក្តីផ្តើម៖**

នៅព្រឹកថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសលើកទី៦ សម្រាប់ឆ្នាំ២០១៦ ក្រោមការដឹកនាំរបស់ **ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៅបន្ទប់ប្រជុំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ព្រមទាំងតំណាងអង្គការមិនមែនរដ្ឋាភិបាល ចំនួន៣៥រូប ។ កិច្ចប្រជុំនេះទទួលបានការឧបត្ថម្ភពីថវិកាជាតិ។

## **២. គោលបំណងនៃកិច្ចប្រជុំ៖**

ដើម្បីបង្ហាញពីរបាយការណ៍វឌ្ឍនភាព សមិទ្ធផល និងទិសដៅបន្តក្នុងការឆ្លើយតបទៅនឹងការរីករាលដាលមេរោគអេដស៍ ព្រមទាំងពិភាក្សា សម្របសម្រួលការងារបច្ចេកទេសតាមរបៀបវារៈដូចខាងក្រោម៖

-មតិស្វាគមន៍ និងគោលបំណង នៃកិច្ចប្រជុំ

-របាយការណ៍ប្រចាំខែ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

-បទបង្ហាញពីការត្រៀមរៀបចំសិក្ខាសាលា ក្នុងការបញ្ជ្រាបសារស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់សិល្បករ សិល្បការិនី សម្រាប់ជួយផ្សព្វផ្សាយបន្តក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក និងសកម្មភាពផ្សព្វផ្សាយពីការបង្ការ ការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។

-បទបង្ហាញពីការត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៦ និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងលើកទិសដៅផែនការសកម្មភាពសម្រាប់ឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៦។

-និងបញ្ហាផ្សេងៗ

## **៣. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ៖**

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម វេជ្ជបណ្ឌិត តែង គន្ធី** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណ ដល់សមាជិក-សមាជិកា ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ ដែលបានអញ្ជើញចូលរួមនាពេលនេះ ហើយកិច្ចប្រជុំនឹងប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុក។

**<u>ប្រធានបទទី១</u>៖ ឯកឧត្តម វេជ្ជបណ្ឌិត ជា ចៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីរបាយការណ៍សង្ខេប របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានធ្វើក្នុងខែកញ្ញា និងខែតុលា ឆ្នាំ២០១៦ ដូចខាងក្រោម៖

- នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមួយជាមួយសមាគមអ្នកសិល្បករ សាលារាជធានីភ្នំពេញ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងព័ត៌មាន ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងអង្គការសង្គមស៊ីវិល ដើម្បីពិភាក្សាត្រៀមរៀបចំការផ្សព្វផ្សាយពីជំងឺអេដស៍ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានត្រៀមរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយលើកទី២ និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅបន្តសម្រាប់ឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៣-២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ នាទីស្តីការគណៈរដ្ឋមន្ត្រី។
- នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៃក្រុមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ នៅភោជនីយដ្ឋានទន្លេបាសាក់២ ដោយបានបង្ហាញពីរបាយការណ៍វឌ្ឍនភាពនៃត្រីមាសកន្លងមករបស់ក្រុមការងារបច្ចេកទេស ការផ្តល់សេវាសុខភាព និងការស្រាវជ្រាវលើក្រុមស្រីស្រស់នាឆ្នាំ២០១៦ ដែលបង្ហាញនូវប្រេវ៉ាឡង់មេរោគអេដស៍ខ្ពស់ជាង(៥.៩)និងបានលើកទិសដៅបន្តសម្រាប់ចូលរួមលុបបំបាត់ការរើសអើង និងមាក់ងាយ នៅកម្ពុជា ។
- បានរៀបចំលិខិតស្តីពីសំណើសុំផ្តល់របាយការណ៍សកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆមាសទី២ ឆ្នាំ២០១៦ សម្រាប់ផ្ញើជូនបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជធានី-ខេត្ត ក្នុងការផ្តល់របាយការណ៍នេះ មកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ នៅខេត្តបាត់ដំបង មានកិច្ចប្រជុំពិភាក្សាកម្មវិធីប្រើប្រាស់ស្រោមអនាម័យ ១០០ ភាគរយ និងជម្រុញការអនុវត្តនូវសេចក្តីជូនដំណឹងលេខ៦៦ ស.ជ.ណ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលស្តីពីការប្រើប្រាស់ស្រោមអនាម័យ ១០០ ភាគរយ ក្រោមអធិបតីភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមការឧបត្ថម្ភគាំទ្រពីអង្គការ PSK ដោយមានការចូលរួមពីសមាជិក-សមាជិកាគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់ ព្រមទាំងម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្នុងខេត្តបាត់ដំបង។
- នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមកិច្ចប្រជុំជាមួយគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ក្នុងគោលបំណងពិនិត្យពីស្ថានភាពការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមប្រឈមមុខខ្ពស់ និងកិច្ចសហការរវាងអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ ព្រមទាំងបានចូលរួមដោះស្រាយបញ្ហាប្រឈមមួយចំនួនដែលទាក់ទងទៅនឹងការប្រយុទ្ធនឹងជំងឺអេដស៍។

- នៅថ្ងៃទី២៥ ដល់ទី២៨ ខែកញ្ញា ឆ្នាំ២០១៦ នៅខេត្តបាត់ដំបង អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការរាយការណ៍ និងចងក្រងជាឯកសារក្នុងករណីរំលោភបំពានលើក្រុមប្រឈមមុខខ្ពស់ ក្នុងកម្មវិធី MCPI ក្រោមអធិបតីភាពឯកឧត្តម វេជ្ជបណ្ឌិត **ទា ផលា** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៦ នាខេត្តសៀមរាប អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចូលរួមធ្វើបទបង្ហាញក្នុងសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍ ដែលរៀបចំដោយ**ក្រសួងទេសចរណ៍។**
- **ក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា** បានបើកសិក្ខាសាលាស្តីពីការគ្រប់គ្រងជនអនាថា និងកុមារងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ ដោយបានធ្វើបទបង្ហាញពីផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងបច្ចុប្បន្នភាពនៃការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ។
- នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាស ក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិប្រយុទ្ធនឹងជំងឺអេដស៍ នៃក្រុមបុរសរួមភេទជាមួយបុរស និងស្រីស្រស់ នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីពិនិត្យមើលពីស្ថានភាពការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមក្រុមស្រីស្រស់ និងកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីចូលរួមដោះស្រាយបញ្ហាប្រឈម និងលុបបំបាត់ការរើសអើង។
- អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំពង្រាងទម្រង់លិខិតសរសើរ និងវិញ្ញាបនបត្របញ្ជាក់ការចូលរួមសិក្ខាសាលាក្នុងការបញ្ជ្រាបសារស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់សិល្បករ សម្រាប់ផ្សព្វផ្សាយបន្តក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦ និងលិខិតថ្លែងអំណរគុណដល់អង្គការ KHANA អង្គការ PSK និងអង្គការ AHF។
- ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំជាមួយអង្គការសង្គមស៊ីវិល ដើម្បីត្រៀមរៀបចំផ្សព្វផ្សាយពីបញ្ហាអេដស៍ នាឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក និងទិវាអេដស៍ពិភពលោក ១ធ្នូ ឆ្នាំ២០១៦។
- នៅថ្ងៃទី០៣ ដល់០៤ ខែតុលា ឆ្នាំ២០១៦ បានចូលរួមកិច្ចប្រជុំបច្ចេកទេសទ្វេភាគីកម្ពុជាថៃ ស្តីពីការពង្រឹងសហប្រតិបត្តិការលើការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ចំពោះពលករចំណាកស្រុកឆ្លងកាត់ព្រំដែនទៅប្រទេសថៃ។ ជាលទ្ធផលយើងបានពង្រឹងកិច្ចសហការជាមួយគ្នា ផ្តល់ការគាំទ្រដល់ពលករចំណាកស្រុកឆ្លងកាត់ព្រំដែនទៅប្រទេសថៃ ឲ្យទទួលបានសេវាបង្ការ និងថែទាំបន្តក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍បានកាន់តែប្រសើរឡើង។

- ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ នៅសណ្ឋាគារកាំបូឌីយ៉ាណា ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំគណៈប្រតិភូ ចូលរួមកិច្ចប្រជុំពិភាក្សាទ្វេភាគីរវាង កម្ពុជា-ចិន ស្តីពីបទពិសោធន៍ក្នុងការឆ្លើយតបអំពីមេរោគអេដស៍ និងជំងឺអេដស៍របស់ប្រទេសទាំងពីរ។
- ថ្ងៃទី២០ និង២៥ ខែតុលា ឆ្នាំ២០១៦ ក្រសួងទេសចរណ៍បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយពីច្បាប់អេដស៍ និងស្ថានភាពរីករាលដាលមេរោគអេដស៍ និងផលប៉ះពាល់នៅកម្ពុជា ក្នុងវិស័យទេសចរណ៍ នាខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ។

<u>**ផែនការសកម្មភាព និងទិសដៅបន្ត៖**</u>

- បន្តធ្វើការប្រមូល និងបូកសរុបរបាយការណ៍សកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ប្រចាំឆមាសទី២ ឆ្នាំ២០១៦ ពីបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងរាជធានី-ខេត្ត សម្រាប់ត្រៀមដាក់បង្ហាញនៅក្នុងកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៦។
- រៀបចំសិក្ខាសាលាដើម្បីបញ្ជ្រាបសារអប់រំស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់សិល្បករ និងអ្នកសារព័ត៌មាន សម្រាប់ផ្សព្វផ្សាយបន្តក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នាថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៦។
- រៀបចំប្រារព្ធពិធីបើកយុទ្ធនាការអប់រំ និងការប្រគំតន្ត្រី ឆាកកំប្លែង ដើម្បីផ្សព្វផ្សាយ ពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៦។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាគោលនយោបាយលើកទី២ និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៦ និងទិសដៅបន្តសម្រាប់ឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តិទៅនៅថ្ងៃទី២៣-២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ នាទីស្តីការគណៈរដ្ឋមន្ត្រី។
- ត្រៀមរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៦។

ក្រោយពីបង្ហាញចប់ ឯកឧត្តមប្រធានអង្គប្រជុំ បានស្នើអោយបន្ថែមនូវសកម្មភាពដែលសមាជិកក្រុមការងារបានធ្វើកន្លងមក សម្រាប់ដាក់បញ្ចូលទៅក្នុងរបាយការណ៍ប្រចាំខែរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

<u>**តំណាងកាកបាទក្រហមកម្ពុជា៖**</u> ប្រធានបទដែលត្រូវបានកំណត់សម្រាប់ទិវាឥស្សរជនឆ្នើមថ្នាក់ជាតិ ឆ្នាំ២០១៦គឺ **យុវជនកម្ពុជា ប្តេជ្ញារួមចំណែកការពារមិនឲ្យឆ្លងអេដស៍** ហើយនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ នឹងមានការរៀបចំចតទិវាឥស្សរជនឆ្នើមថ្នាក់ជាតិ នៃវេទិកាភាពជាអ្នកដឹកនាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ចំពោះការឆ្លើយតបមេរោគអេដស៍-ជំងឺអេដស៍នៅកម្ពុជា ឆ្នាំ២០១៦ នៅស្ទូឌីយោទ.ទ.ក។

<u>**តំណាងក្រសួងទេសចរណ៍**</u>៖ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីច្បាប់អេដស៍ និងស្ថានភាពរីករាលដាលមេរោគអេដស៍ និងផលប៉ះពាល់នៅកម្ពុជា ក្នុងវិស័យទេសចរណ៍ នៅខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ។

**តំណាងក្រសួងការពារជាតិ៖** បានរៀបចំលិខិត និងបែបបទរដ្ឋបាលសម្រាប់ដាក់ជូនទៅថ្នាក់ដឹកនាំក្រសួង ដើម្បីសុំការអនុញ្ញាតក្នុងការអនុវត្តសកម្មភាពទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដោយមានការឧបត្ថម្ភគាំទ្រពីអង្គការ AHF។

**តំណាងក្រសួងអភិវឌ្ឍន៍ជនបទ៖** បានបញ្ជ្រាបការផ្សព្វផ្សាយពីមេរោគអេដស៍ និងជំងឺអេដស៍ តាមរយៈការចុះមូលដ្ឋានរបស់ថ្នាក់ដឹកនាំក្រសួង និងតាមរយៈក្រុមគ្រូពេទ្យស្ម័គ្រចិត្តបារាំង ដែលចុះព្យាបាលជូនប្រជាជនដោយឥតគិតថ្លៃ នៅឃុំឈានឡើង ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង។

**តំណាងក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ** ៖ ស្នើអោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ចេញជាលិខិតទៅក្រសួង អោយមានការចូលរួមពីសិល្បករ សិល្បការិនី តាមរយៈសកម្មភាពផ្សេងៗ ក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍។

**តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ៖** ការធ្វើជាល្ខោនសហគមន៍ ដោយជ្រើសរើសអ្នកសំដែងពីភូមិ ឃុំ សម្រាប់ផ្សព្វផ្សាយបន្ត ទៅដល់អ្នកចូលរួមនៅទីនោះ គឺទទួលបាននូវប្រសិទ្ធិភាពខ្ពស់។

**តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម៖** បានចុះផ្សព្វផ្សាយពីការប្រយុទ្ធទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍ ដល់អនុគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តបាត់ដំបង ដោយមានការចូលរួមពីម្ចាស់រោងចក្រ-សិប្បកម្មផងដែរ។

**តំណាងក្រសួងពាណិជ្ជកម្ម៖** របាយការណ៍សកម្មភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍គិតត្រឹមថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១៦បានផ្សព្វផ្សាយពីវឌ្ឍនភាពនៃការប្រយុទ្ធនឹងជំងឺអេដស៍ និង ផ្សព្វផ្សាយសេចក្តីសម្រេចចិត្តនៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០១៦ ជូនថ្នាក់ដឹកនាំក្រសួង អគ្គនាយក អគ្គនាយករង ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋានក្រោមចំណុះក្រសួងពាណិជ្ជកម្ម។

**ប្រធានបទទី២៖ ឯកឧត្តម វេជ្ជបណ្ឌិត ឌា ចៅ** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីគម្រោងរៀបចំយុទ្ធនាការអប់រំផ្សព្វផ្សាយពីមេរោគអេដស៍និងជំងឺអេដស៍ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៦ ដោយមានការបែងចែកជា២ដំណាក់កាលគឺ៖

១-ការរៀបចំសិក្ខាសាលា ក្នុងការបញ្ជ្រាបសារស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ ដល់សិល្បករសម្រាប់ផ្សព្វផ្សាយបន្តក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និង សំពះព្រះខែ អកអំបុក ក្នុងគោលបំណងបង្កើនចំណេះដឹងពីមេរោគអេដស៍/ជំងឺអេដស៍ ជូនដល់អ្នកសិល្បករ និងអ្នកសារព័ត៌មាន ដើម្បីអោយពួកគាត់ជួយបញ្ជ្រាបទៅដល់ប្រជាពលរដ្ឋទូទៅ ពិសេសក្រុមប្រឈមមុខខ្ពស់ អ្នកងាយរងគ្រោះ និងកុំអោយមានការរើសអើង និងមាក់ងាយចំពោះអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

២-ការប្រារព្ធពិធីបើកយុទ្ធនាការអប់រំ ផ្សព្វផ្សាយពីមេរោគអេដស៍/ជំងឺអេដស៍ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០១៦ ដោយមានការរៀបចំនៅមុខអគារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ នារសៀលថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ និងពីថ្ងៃទី១៣-១៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ជាកម្មវិធីប្រគំតន្ត្រីអប់រំផ្សព្វផ្សាយពីមេរោគអេដស៍/ជំងឺអេដស៍ នៅត្រើយខាងកើតទន្លេ ទល់មុខព្រះបរមរាជវាំង៖

-មានការរៀបចំកន្លែងសម្រាប់ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ការដាក់តាំងសម្ភារៈផ្សព្វផ្សាយអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍។

-ការប្រគំតន្ត្រី ការផ្តល់សារអប់រំ និងសំណួរ-ចម្លើយ និងការផ្តល់រង្វាន់លើកទឹកចិត្ត

-ការសំដែងឆាកកំប្លែងអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ និងការផ្តល់សារអប់រំពីមេរោគអេដស៍ និងជំងឺអេដស៍ ពីសិល្បករដែលបានចូលរួមសំដែង។

<u>**ប្រធានបទទី៣៖**</u> **ឯកឧត្តម ឈឹម ឃិនដារ៉េត** អគ្គលេខាធិការរង អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានជម្រាបជូនពីព្រឹត្តការណ៍សំខាន់ៗចំនួន៣ សម្រាប់រៀបចំនៅចុងឆ្នាំ២០១៦៖

១-កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២ ប្រចាំឆ្នាំ២០១៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ នាទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនូវរបាយការណ៍វឌ្ឍនភាពក្នុងការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ដែលបានអនុវត្តកន្លងមក និងពិនិត្យឡើងវិញនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និង ធនធានឲ្យបានសមស្របទៅនឹងសេចក្តីត្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋកម្ពុជា ដែលរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ នាពេលបច្ចុប្បន្ន។

២-សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០១៦ និងលើកទិសដៅផែនការសកម្មភាពប្រចាំឆ្នាំ២០១៧ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ នាទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីចងក្រងនូវរបាយការណ៍វឌ្ឍនភាព ប្រសិទ្ធិភាព និងសមិទ្ធិផលនៃការឆ្លើយតបជាតិទូលំទូលាយ និង ពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៦ និង ការប្រើប្រាស់នូវលទ្ធផលដែលទទួលបានពីឆ្នាំ២០១៦ ទៅរៀបចំនូវគម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និង ពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៧។

៣-ការរៀបចំប្រារព្ធទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ០១ ធ្នូ ឆ្នាំ២០១៦ នាថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៦ នៅសាលសន្និសីទចតុមុខ ក្រោមប្រធានបទ **ឆ្ពោះទៅសម្រេចបាននូវគោលដៅ ៩០-៩០-៩០** ក្នុងគោលបំណង៖

-ដើម្បីផ្សព្វផ្សាយអំពីការវិវឌ្ឍន៍នៃស្ថានភាពមេរោគអេដស៍ និង ជំងឺអេដស៍នៅកម្ពុជា។

-ជំរុញការចូលរួមក្នុងការអនុវត្តគម្រោងផែនការសកម្មភាព ប្រកបដោយប្រសិទ្ធិភាព និងស័ក្តិសិទ្ធភាពនៃការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និង ជំងឺអេដស៍។

-ជំរុញការកៀងគរធនធានគ្រប់ប្រភពសម្រាប់ការងារប្រយុទ្ធនឹងជំងឺអេដស៍។

កិច្ចប្រជុំបានបញ្ចប់នៅវេលាម៉ោង១១ និង៣០នាទី ថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលបំផុត។

ភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦

បានឃើញ និងឯកភាព

**អគ្គលេខាធិការ**

**ប្រធាននាយកដ្ឋាន**

**ទាក់ទង និងចលនាប្រភពធនធាន**

3-11-16